**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**គណៈរដ្ឋមន្ត្រី**

ក្រសួងបរិស្ថាន

លេខៈ ០៣៧ សស [illegible] ប.ស្ថ.កអជ

លិខិតចូល

ថ្ងៃទី 13 ខែ 6 ឆ្នាំ2006

រាជធានីភ្នំពេញ. ថ្ងៃទី ០១ ខែ មិថុនា ឆ្នាំ២០០៦

# សារាចរណែនាំ

## ស្តីពីការគ្រប់គ្រង និងប្រើប្រាស់អាវុធនៅតាមតំបន់ការពារធម្មជាតិ

ដើម្បីអនុវត្តបទបញ្ជា គោលការណ៍ណែនាំរបស់រាជរដ្ឋាភិបាលកម្ពុជា និងក្រសួងមហាផ្ទៃក្នុងការគ្រប់គ្រង និងប្រើប្រាស់អាវុធសម្រាប់ទប់ស្កាត់ បង្ក្រាបបទល្មើសគ្រប់រូបភាពនៅតាមតំបន់ការពារធម្មជាតិក្នុងទូទាំងព្រះរាជាណាចក្រកម្ពុជា ឱ្យបានសមស្របតាមការណែនាំ និងគោលការណ៍របស់ក្រសួងមហាផ្ទៃបានដាក់ចុះ ក្រសួងបរិស្ថានសូមធ្វើការណែនាំ និងដាក់ចេញនូវបទបញ្ជាដូចខាងក្រោមៈ

១. មន្ត្រីបរិស្ថាន និងឧទ្យានុរក្សដែលប្រចាំការនៅតាមតំបន់ការពារធម្មជាតិទាំងអស់អាចប្រើប្រាស់អាវុធបាន តែនៅក្នុងពេលចុះបំពេញបេសកកម្មល្បាត ទប់ស្កាត់ បង្ក្រាបបទល្មើស និងភាពអនាធិបតេយ្យគ្រប់រូបភាពនៅក្នុងតំបន់ការពារធម្មជាតិនោះ ដោយភ្ជាប់ជាមួយនូវលិខិតបញ្ជាបេសកកម្មត្រឹមត្រូវពីក្រសួងបរិស្ថាន។

២. ក្នុងពេលបំពេញបេសកកម្ម ហាមដាច់ខាតការបាញ់ចោះ លើកលែងក្នុងករណីពិសេស ដែលត្រូវការពារខ្លួន នូវគ្រោះថ្នាក់ចំពោះមុខ។

៣. ក្រោយពីបញ្ចប់បេសកកម្ម នាយក នាយករង មន្ត្រីបរិស្ថាន និងឧទ្យានុរក្សដែលប្រចាំការនៅតាមតំបន់ការពារធម្មជាតិនោះ ត្រូវប្រមូលអាវុធទាំងអស់បញ្ចូលឃ្លាំងរក្សាទុកឱ្យបានគត់មត់ល្អ ដោយមានការចុះបញ្ជីបានត្រឹមត្រូវ និងច្បាស់លាស់។

៤. ករណីបាត់អាវុធ និងគ្រាប់រំសេវគ្រប់ប្រភេទដែលបាន និងកំពុងកាន់កាប់ប្រើប្រាស់ ត្រូវរាយការណ៍មិនលើសពីម្ភៃបួន (២៤)ម៉ោងក្រោយពេលដឹងថាបាត់ ដល់សមត្ថកិច្ចនគរបាលរដ្ឋបាលឃុំសង្កាត់ ឬកងរាជអាវុធហត្ថនៅទីងកន្លែងដែលជិតបំផុត ហើយត្រូវមានសាក្សីដឹងឮម្នាក់ ឬពីរនាក់ទៅជាមួយ។

៥. រាល់របាយការណ៍ស្តីពីការបាត់អាវុធ និងគ្រាប់រំសេវគ្រប់ប្រភេទត្រូវធ្វើជាលាយលក្ខណ៍អក្សរ ដោយបញ្ជាក់លំអិតពី ប្រភេទអាវុធ និងគ្រាប់រំសេវ លេខចុះបញ្ជី ព្រមទាំងមូលហេតុ និងពេលវេលានៃការបាត់នោះ។

៦. នាយក នាយករង មន្ត្រីបរិស្ថាន និងឧទ្យានុរក្សប្រចាំការតាមតំបន់ការពារធម្មជាតិ ដែលមានសិទ្ធិប្រើប្រាស់អាវុធទាំងអស់ ត្រូវបានហាមដាច់ខាតនូវរាល់ការលក់ ការផ្ទេរ ឬឱ្យខ្ចីអាវុធ និងគ្រាប់រំសេវគ្រប់ប្រភេទទៅឱ្យបុគ្គលណាមួយ ទោះក្នុងករណីណាក៏ដោយ។

៧. នាយកតំបន់ការពារធម្មជាតិនីមួយៗ ត្រូវទទួលខុសត្រូវក្នុងការគ្រប់គ្រង និងប្រើប្រាស់អាវុធ គ្រាប់រំសេវក្នុងតំបន់ការពារធម្មជាតិរបស់ខ្លួនឱ្យបានហ្មត់ចត់។

៨. ក្នុងករណីអនុវត្តផ្ទុយពីការណែនាំ និងបទបញ្ជាខាងលើ សាមីខ្លួនដែលមានសិទ្ធិប្រើប្រាស់អាវុធ ត្រូវទទួលខុសត្រូវចំពោះមុខច្បាប់ជាធរមាន។

៩. បានទទួលសារាចរណែនាំនេះ អគ្គនាយកបច្ចេកទេស ប្រធាននាយកដ្ឋានការពារ និងអភិរក្សធម្មជាតិ ប្រធានមន្ទីរបរិស្ថានខេត្ត ក្រុងពាក់ព័ន្ធ នាយក នាយករង និងឧទ្យានុរក្សប្រចាំការតាមគ្រប់តំបន់ការពារធម្មជាតិទាំងអស់ ត្រូវទទួលបន្ទុកអនុវត្តឱ្យមានប្រសិទ្ធភាពខ្ពស់ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងបរិស្ថាន

ម៉ុក មារ៉េត

បណ្ឌិត.ពិសិដ្ឋ

__ចម្លងជូន:__

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងមហាផ្ទៃ
- ក្រសួងការពារជាតិ
- ក្រសួងយុត្តិធម៌
- អភិបាលខេត្ត ក្រុងពាក់ព័ន្ធ
- ដូចប្រការ ៧ "ដើម្បីអនុវត្ត"
- ឯកសារ.កាលប្បវត្តិ